**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ១១.០៤៧/០៧ គ.ជ.ប.អគ្គ.ពស** ភ្នំពេញ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧

# ក្រុមប្រឹក្សាជំនុំជំរះ (គ.ជ.ប) សម្រេចលុបឈ្មោះចំនួន ៥៦ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូង

នៅថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ក្រុមប្រឹក្សាជំនុំជំរះ (គ.ជ.ប) បានបើកសវនាការជាសាធារណៈ ដោះស្រាយបណ្តឹងរបស់លោក ផេង កៅ តំណាងគណបក្សសម រង្ស៊ី ដែលប្តឹងសុំលុបឈ្មោះប្រជាពលរដ្ឋចំនួន ៥៦ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូង នៅឃុំ រកាកោងមួយ ស្រុក មុខកំពូល ខេត្ត កណ្តាល ដោយចោទប្រកាន់ថា អ្នកទាំងនោះជាជនបរទេស ។

បន្ទាប់ពីសវនាការសួរដេញដោលអស់ពេលជាង ១ ម៉ោង រួចមក ក្រុមប្រឹក្សាជំនុំជំរះ គ.ជ.ប ក៏បានថយទៅពិចារណា។ បន្ទាប់មកក្រុមប្រឹក្សាជំនុំជំនះក៏បានធ្វើការសម្រេចទទួលយកពាក្យបណ្តឹងចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៧ របស់ដើមប្តឹង ឈ្មោះ ផេង កៅ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។ បដិសេធសេចក្តីសម្រេចចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៧ របស់ក្រុមប្រឹក្សាឃុំ រកាកោងមួយចោលជាអាសាបង់ ។ សម្រេចលុបឈ្មោះក្នុងបញ្ជីបោះឆ្នោតចំនួន ៥៦ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូងនៅឃុំ រកាកោងមួយ ស្រុក មុខកំពូល ខេត្ត កណ្តាល ។

ការសម្រេចលុបឈ្មោះចំនួន ៥៦ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូងនេះ ដោយក្រុមប្រឹក្សាជំនុំជំរះ ( គ.ជ.ប ) ផ្អែកលើមាត្រា ៥៤ ថ្មី និងមាត្រា ៦៤ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ។